-អតីតអធិការកិច្ចរាជរដ្ឋាភិបាល ត្រូវប្រគល់ការិយាល័យ និងអគារនានាព្រមទាំងសម្ភារការិយាល័យទាំងអស់ អោយមកស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤ .- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

## អនុក្រឹត្យ លេខ ៨១ អនក្រ-បក

## ស្តីពីការផ្ទេរអតីតអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អោយស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួងធនធានទឹក និង ឧតុនិយម

*****

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩

### សំរេច

មាត្រា ១ .- ត្រូវបានផ្ទេរអតីតអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ និងបណ្តាការិយាល័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ នៅតាមបណ្តាខេត្ត-ក្រុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រួមទាំងចលនទ្រព្យ និងអចលនទ្រព្យ និងក្របខ័ណ្ឌមន្ត្រីរាជការទាំងអស់អោយស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ២ .-** ក្នុងករណី លើកលែងការិយាល័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ នៅតាមខេត្ត-ក្រុង ណាមានពីរ មុខងារនោះ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងតំណាងក្រសួង ធនធានទឹក និងឧតុនិយម ត្រូវពិភាក្សាដោះស្រាយដោយគោលការណ៍ឯកភាព ។

**មាត្រា ៣ .-** អតីតអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ និងមណ្ឌលការិយាល័យ តាមខេត្ត-ក្រុង ដែលមានចែងក្នុងមាត្រា១ខាងលើ សំរាប់ធ្វើជាទីស្តីការ ក្រសួងធនធានទឹកនិងឧតុនិយម និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្ត-ក្រុង ។

**មាត្រា ៤ .-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

=====

## អនុក្រឹត្យ លេខ ៨២ អនក្រ-បក

## ស្តីពីការផ្ទេរទីស្តីការនៃអតីត ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអាគារ អតីតស្ថាប័នយុវនីតិសម្បទា អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

* * * * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨